ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានសម្រាប់ក្រុមបុរសស្រឡាញ់បុរស

## ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២

## ចាប់ពីម៉ោង: ១៤:៣០ រហូតដល់ម៉ោង ១៧:០០ ល្ងាច

**១.គោលបំណង**

-ពិនិត្យ និងពិភាក្សាលើការរៀបចំកម្មវិធីនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស នៅកម្ពុជា។

**២.កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន**

-កាលបរិច្ឆេទ:ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១២

-ទីកន្លែង:នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-វត្តមាន: អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ RHAC BC N KHANA UNESCO MSIC KDFO and CSSD

-អវត្តមាន: FHI360 PSI UNAIDS (confirm for absence) MHSS MHC Pact Cambodia and KANHNHA

**៣.វិធីសាស្ត្រ**

-ជួបពិភាក្សាជាមួយសមាជិកក្រុមការងារលេខាធិការដ្ឋានក្រុមបុរសស្រឡាញ់បុរស

**៤.លទ្ធផល**

កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុម ការងារលេខាធិការដ្ឋាន សម្រាប់ក្រុមបុរសស្រឡាញ់បុរស ស្តីពីការពិនិត្យមើលបន្តពីកិច្ចប្រជុំលើកមុនក្នុងការ ប្រមូលបទអន្តរាគមន៍ និងទំហំថវិកា នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស នៅកម្ពុជា។ អញ្ជើញចូលរួមដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ដោយឯកឧត្តម វេជ្ជ. តែង គន្ធី អគ្គលេខាធិការអាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស។ ជាកិច្ចចាប់ផ្តើម ឯកឧត្តម បានស្វាគមន៍ និង អរគុណយ៉ាងជ្រាវជ្រៅចំពោះវត្តមាន សមាជិកក្រុមការងារលេខាធិការដ្ឋាន បុរសស្រឡាញ់បុរស ដែលបានចំណាយពេលវេលាចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងារ។ ប្រធាន បទសំខាន់ដែលលើក

យកមកពិភាក្សាថ្ងៃនេះ ពិនិត្យ និងពិភាក្សាលើការរៀបចំកម្មវិធីនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស នៅកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២៩០១២ និងបញ្ហាផ្សេងៗទៀត ។ អង្គប្រជុំបានពិភាក្សាលំអិតទៅតាមចំនុចនីមួយៗនៃប្រធានបទ និងបានសំរេចលទ្ធផល ដូចខាងក្រោម:

- កិច្ចប្រជុំប្រចាំត្រីមាសលើកទីពីរ នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិក្រុមបុរសស្រឡាញ់បុរស នឹងរៀបចំនៅ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ដោយមានប្រធានបទដូចខាងក្រោម

- បទបង្ហាញពីសមិទ្ធិផលសកម្មភាពការងារបុរសស្រឡាញ់បុរសនៅកម្ពុជា ដែលបានសំរេច និងបញ្ហា ព្រមទាំងឧបសគ្គនានាដែលបានជួបប្រទះ ក្នុងពេលអនុវត្តការងាររយៈពេលប្រាំមួយខែដើមឆ្នាំ ។

-បទបង្ហាញពីបទអន្តរាគមន៍ដែលកំពង់អនុវត្តលើក្រុមបុរសស្រឡាញ់បុរស នៅកម្ពុជា

-បទបង្ហាញពីការពិនិត្យមើលនូវតួនាទី និងភារៈកិច្ចក្នុងការរៀបចំផែនការប្រតិបត្តិ

-បទបង្ហាញពីវឌ្ឍនភាព និងកែសំរួលយន្តការរបស់បណ្តាញចតុមុខ

-បទបង្ហាញពីវឌ្ឍនភាពតំណាងក្រុមបុរសស្រឡាញ់បុរសនៅក្នុង (CCC) ដែលរៀបចំដោយអង្គការKHANA ។

- ស្នើសុំឱ្យសមាជិកក្រុមការងារលេខាធិការដ្ឋានរៀបចំនូវរបាយការណ៍សមិទ្ធិផលដែលបានសំរេច និងឧបសគ្គ ព្រមទាំងបំពេញនូវបទអន្តរាគមន៍ដែលកំពង់អនុវត្តលើក្រុមបុរសស្រឡាញ់បុរសនៅកម្ពុជា ។

ជាទីបញ្ចប់ ឯកឧត្តម អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងអំណរគុណ និងកោត សរសើរចំពោះ ការខិតខំប្រឹងប្រែងរបស់សមាជិក ដែលជាសកម្មជនដែលបាន សហការគ្នា ល្អធ្វើឱ្យការងារឆ្លើយ តបទៅការ ទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ទទួលលទ្ធផលគួរឱ្យកោតសរសើរទោះបី មានជួបបញ្ហាមួយចំនួនក៏ដោយ ។

ភ្នំពេញថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២

អ្នកធ្វើរបាយការណ៍

ហ៊ឹម សុវណ្ណារ៉ា

បានឃើញ និងពិនិត្យ

ប្រធាននាយកដ្ឋានបង្ការ ថែទាំ និងគាំទ្រ

បានឃើញ និងឯកភាព

អគ្គលេខាធិការ